**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ : ....២០៨.......... បទ.ប្រក

"....ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព"

# ប្រ កា ស

## ស្តីពី

## ការទទួលស្គាល់យថាប្រភេទ (TYPE APPROVAL) លើបរិក្ខារវិទ្យុគមនាគមន៍ និងបរិក្ខារទូរគមនាគមន៍

~~~~~~~~~~~

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងប្រពឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ២០/អនក្រ/បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រពឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ០៥/អនក្រ/បក ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ១៩៩៧ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីស្តីពីប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៦៦/អនក្រ/បក ចុះថ្ងៃទី ២២ ខែតុលា ឆ្នា១៩៩៧ ស្តីពីការរៀបចំនិងប្រពឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៨៦អនក្រ.បក ចុះថ្ងៃទី ១៩ខែ សីហា ឆ្នាំ ២០០២ ស្តីពីការកែសំរួល និងបំពេញបន្ថែមនាយកដ្ឋានមួយចំនួន នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៣ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និង បណ្តុះបណ្តាលទៅជាអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញប្រកាសលេខ ០៧២ ប.ទ.ប្រក. ស្តីពីការគ្រប់គ្រងបរិក្ខារវិទ្យុគមនាគមន៍ និងថ្លៃសេវាប្រើប្រាស់រលកអាកាសវិទ្យុ

កាច់ជ្រុងវិថីលេខ ១៣ និង ១០២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ

ទូរស័ព្ទ : (៨៥៥) ២៣_៧២៤៨០៩/៤២៨២៤៦

ទូរសារ : (៨៥៥) ២៣_៤២៦៥៤១/៤២៦០០៥/៧២៤៨០៩
~~~~~~~~~~~

- បានឃើញសេចក្តីសំរេចលេខ ១៥៤ សសរ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីស្តីពីឋានានុក្រមគ្រប់គ្រងតម្លៃ ។

## ស ម្រេ ច

**ប្រការ ១ :** រាល់បរិក្ខារវិទ្យុគមនាគមន៍ និងបរិក្ខារទូរគមនាគមន៍ត្រូវមានការទទួលស្គាល់យថាប្រភេទ **(Type Approval)** ពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍មុននឹងដាក់អោយធ្វើចរាចរលើទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ២ :** រាល់បទបញ្ញត្តិនៃប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវទុកជា និរាករណ៍ ។

**ប្រការ ៣ :** អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍ អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋានពាក់ព័ន្ធ និងគ្រប់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ រាជធានី-ខេត្ត ក្រោមឱវាទក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវទទួលបន្ទុកអនុវត្តតាមតួនាទី និង ភារកិច្ចនូវប្រកាសនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ ៤ :** ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ២០១០

**រ ដ្ឋ ម ន្ត្រី**

**កន្លែងទទួល**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភាជាតិ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងផែនការ
  "ដើម្បីជ្រាបជាព័ត៌មាន"
- ដូចប្រការ ៣
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

| នាយកដ្ឋាន ... | |
|---|---|
| ចូល | លេខ......៥០៨......ម ខ ទំ |
| | ថ្ងៃទី ០៤ ខែ ១០... ឆ្នាំ២០០០... |
| | ម៉ោង...9:45 AM........ |

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
លេខ : ១៧២ បទ.ប្រក

"...ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព

# ប្រកាស
## ស្តីពី
## ការធ្វើប្រតិភូកម្មអំណាចជូនមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ក្នុងការគ្រប់គ្រងសេវាអ៊ីនធឺណេតកាហ្វេ និងចិត្តគមនាគមន៍

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ខែកញ្ញាឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ខែមករាឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ៦៦អនក្រ.បក ចុះថ្ងៃទី២២ខែតុលាឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិង
- ការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ៨៦អនក្រ.បក ចុះថ្ងៃទី១៩ខែសីហាឆ្នាំ២០០២ ស្តីពីការកែសម្រួល
- និងបំពេញបន្ថែមនាយកដ្ឋានមួយចំនួននៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ០៥អនក្រ.បក ចុះថ្ងៃទី២៨ខែមករាឆ្នាំ២០០៣ ស្តីពីការដំឡើងនាយកដ្ឋានរដ្ឋបាលនិងបណ្តុះបណ្តាលទៅជាអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ១៣អនក្រ/បក ចុះថ្ងៃទី១៧ខែកុម្ភៈឆ្នាំ២០០៦ ស្តីពីការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ១៨១អនក្រ/បក ចុះថ្ងៃទី០៣ខែវិច្ឆិកាឆ្នាំ២០០៨ ស្តីពីការដំឡើងអធិការដ្ឋានទៅជាអគ្គាធិការដ្ឋាន នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញប្រកាសលេខ០២៣ប.ទប្រក ចុះថ្ងៃទី២៨ខែមីនាឆ្នាំ១៩៩៦ ស្តីពីសិទ្ធិនិងការកិច្ចរបស់មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្ត-ក្រុង ក្នុងការគ្រប់គ្រងលេកអាកាសវិទ្យុ
- បានឃើញប្រកាសលេខ១៧៩ បទ.ប្រក ចុះថ្ងៃទី១៨ខែកញ្ញាឆ្នាំ២០០០ ស្តីពីអាជ្ញាប័ណ្ណបើកអាជីវកម្មសាលបម្រើអ៊ីនធឺណេត

កាច់ជ្រុងវិថីលេខ ១៣ និង ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
ទូរស័ព្ទ: (៨៥៥) ២៣-៧២៥៩១០/៤២៦៥១០/
ទូរសារ: (៨៥៥) ២៣-៤២៦៩៥២/៤២៦០១១

- បានឃើញប្រកាសលេខ០៧២ប.ទប្រក ចុះថ្ងៃទី១៩ខែមីនាឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងបរិក្ខារវិទ្យុគមនាគមន៍និងថ្លៃប្រើប្រាស់រលកអាកាសវិទ្យុ
- បានឃើញប្រកាសលេខ១០៥ ប.ទប្រក ចុះថ្ងៃទី១០ខែឧសភាឆ្នាំ២០១០ របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ស្តីពីការបង្កើតក្រុមប្រឹក្សាអ្នកច្បាប់របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- យោងតាមការចាំបាច់របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

## សម្រេច

**ប្រការ ១-**

ប្រកាសនេះមានគោលបំណងប្រគល់សិទ្ធិជូនមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ក្នុងការគ្រប់គ្រង និងផ្តល់លិខិតអនុញ្ញាតដូចមានចែងក្នុងប្រការ ៣។

**ប្រការ ២-**

ពាក្យបច្ចេកទេសទាំងឡាយដែលប្រើប្រាស់ក្នុងប្រកាសនេះមានន័យដូចតទៅ៖

១- លិខិតអនុញ្ញាត ( Authorization Letter )

សំដៅលើលិខិតដែលមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ ផ្តល់ជូនអ្នកស្នើសុំ:

- បើកសាលបម្រើសេវាអ៊ីនធឺណេតកាហ្វេ ( Internet café )។
- លក់-ដូរផុលសម្ភារៈបរិក្ខារវិទ្យុគមនាគមន៍ និង បរិក្ខារទូរគមនាគមន៍។
- ប្រើប្រាស់ហ្វ្រេកង់ស៍ វី-អេជ្ស-អែហ្វ និង យូ-អេជ្ស-អែហ្វ (VHF and UHF) សម្រាប់ដំណើរការស្ថានីយវិទ្យុទាក់ទងក្នុងដែនសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន។

ពាក្យ "លិខិតអនុញ្ញាត" ក្នុងប្រកាសនេះ ប្រើក្នុងកម្រិតសមត្ថកិច្ចរបស់មន្ទីរជំនួសពាក្យ "វិញ្ញាបនប័ត្រ ឬ អាជ្ញាប័ណ្ណ" ដែលបានប្រើក្នុងកម្រិតសមត្ថកិច្ចរបស់ក្រសួង។

២- វិទ្យុទាក់ទង ( Radiocom, Push To Talk ហៅ Icom )

សំដៅលើបរិក្ខារសម្រាប់ទាក់ទងគ្នាដោយប្រើរលកអាកាសវិទ្យុVHFនិងUHF។

៣- វិទ្យុគមនាគមន៍

សំដៅលើទូរគមនាគមន៍តាមរយៈការប្រើប្រាស់រលកអាកាសវិទ្យុ។

៤- បង្គោលអង់តែន ( Antenna Tower )

សំដៅលើបង្គោលដែកឬបំពង់ទីបដែកសម្រាប់បំពាក់អង់តែន។

៥- អង់តែនម៉ាយក្រូវ៉េវ ( Microwave Antennas )

សំដៅលើឧបករណ៍ដែលប្រើរលកអេឡិចត្រូម៉ាញ៉េទិកក្នុងចន្លោះបង់ហ្វ្រេកង់ស៍ចាប់ពី ៣០០មេហ្គាហឺតទៅ ៣០០ ជីហ្គាហឺត។

៦- វី-អេជ្ស-អែហ្វ ( VHF: Very High Frequency )

សំដៅលើបង់ហ្វ្រេកង់ស៍ចាប់ពី ៣០ ទៅ ៣០០ មេហ្គាហឺត។

៧- យូ-អេជ្ស-អែហ្វ ( UHF: Ultra High Frequency )

សំដៅលើបង់ហ្វ្រេកង់ស៍ចាប់ពី ៣០០ ទៅដល់ ៣០០០ មេហ្គាហឺត។

៨- ស្ថានីយវីសាត ( VSAT : Very Small Aperture Terminal )

សំដៅលើស្ថានីយលើដីសម្រាប់បញ្ជូន និងទទួលជាមួយផ្កាយរណប។

៩- សាលបម្រើសេវាអ៊ីនធឺណេតកាហ្វេ ( Internet Café )

សំដៅលើទីកន្លែងបម្រើសេវាអ៊ីនធឺណេតផ្តល់ជូនដល់សាធារណជនប្រើប្រាស់អ៊ីនធឺណេត។

១០- ទូរគមនាគមន៍ ( Telecommunications )

សំដៅលើការផ្សាយ បញ្ជូន ឬ ទទួលសញ្ញាល់ អក្សរ រូបភាព សំឡេង ឬ ព័ត៌មានគ្រប់ប្រភេទតាមមធ្យោបាយខ្សែកាប្លិ៍ តាមអុបទិក តាមវិទ្យុអគ្គិសនី ឬ តាមប្រព័ន្ធអេឡិចត្រូម៉ាញេទិកផ្សេងៗទៀត។

ប្រការ ៣-

មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍មានសិទ្ធិផ្តល់ជូនអ្នកស្នើសុំនូវលិខិតអនុញ្ញាត៖

១- បើកអាជីវកម្មសាលបម្រើសេវាអ៊ីនធឺណេតកាហ្វេ ( Internet café )។

២- លក់-ដូរសម្ភារៈបរិក្ខារវិទ្យុគមនាគមន៍ និង បរិក្ខារទូរគមនាគមន៍ (លើកលែងតែលិខិតអនុញ្ញាតក្នុងការនាំចូល)។

៣- ប្រើប្រាស់ហ្វ្រេកង់ស៍ វី-អេច-អែហ្វ និង យូ-អេច-អែហ្វ ( VHF and UHF ) សម្រាប់ដំណើរការស្ថានីយវិទ្យុទាក់ទងក្នុងដែនសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន។

ករណីអ្នកស្នើសុំប្រើប្រាស់ហ្វ្រេកង់ស៍មានបរិក្ខារវិទ្យុទាក់ទងច្រើនគ្រឿងស្ថិតនៅក្នុងខេត្តណា មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តនោះជាអ្នកចេញលិខិតអនុញ្ញាតជូន ទោះបីបរិក្ខារវិទ្យុទាក់ទងមួយចំនួនតូចស្ថិតនៅក្នុងខេត្តផ្សេងក៏ដោយ។

ប្រការ ៤-

តួនាទីនិងភារកិច្ចរបស់មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍នៅក្នុងក្របខ័ណ្ឌនៃប្រកាសនេះមានដូចខាងក្រោម ៖

១- ទទួលពិនិត្យ និង សម្រេចតាមនីតិវិធីលើរាល់ពាក្យស្នើសុំដែលបានបំពេញតាមការណែនាំរួចហើយ ដើម្បីផ្តល់ជូនម្ចាស់ពាក្យស្នើនូវលិខិតអនុញ្ញាតដូចប្រការ៣ខាងលើនេះ។

២- ត្រូវគិតតម្លៃនៃលិខិតអនុញ្ញាតតាមការណែនាំដែលមានចែងនៅក្នុងប្រកាសលេខ ១៧៩បទ.ប្រក ចុះថ្ងៃទី១៨ខែកញ្ញាឆ្នាំ២០០០ ស្តីពីអាជ្ញាប័ណ្ណបើកអាជីវកម្មសាលបម្រើអ៊ីនធឺណេត និង ប្រកាសលេខ ០៣២ ប.ទប្រក ចុះថ្ងៃទី១៩ខែមីនាឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងបរិក្ខារវិទ្យុគមនាគមន៍ និង ថ្លៃប្រើប្រាស់រលកអាកាសវិទ្យុ។

៣- គ្រប់គ្រង រៃរក្សាសំណុំលិខិត ឯកសារទាំងឡាយរបស់អ្នកស្នើសុំដែលបានទទួលលិខិតអនុញ្ញាតនៅតាមខេត្តនីមួយៗ ហើយត្រូវធ្វើរបាយការណ៍ និង ផ្តល់ស្ថិតិ-ទិន្នន័យប្រចាំខែស្តីពីលទ្ធផលសម្រេចបាន ជូនមកក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

៤- ផ្តល់មកក្រសួង នូវស្ថិតិស្ថានីយវិទ្យុគមនាគមន៍ រួមមាន៖

ក ) បង្គោលអង់តែនវិទ្យុផ្សាយសំឡេង

ខ ) បង្គោលអង់តែនស្ថានីយទូរទស្សន៍

គ ) បង្គោលអង់តែនរបស់ក្រុមហ៊ុនបម្រើសេវាទូរស័ព្ទ

ឃ ) ស្ថានីយរ៉ាដា

ង) រាប់ចំនួនអង់តែនម៉ាយក្រូវ៉េវ ដែលបានបំពាក់លើបង្គោលអង់តែន។

៥- ដោះស្រាយបញ្ហា-វិវាទនិងធ្វើរបាយការណ៍ក្នុងករណីមានការរំខានរលកអាកាសវិទ្យុ។ បើមានបណ្តឹង និង វិវាទធ្ងន់មិនអាចដោះស្រាយបាន មន្ទីរត្រូវបញ្ជូនសំណុំរឿងនោះជាបន្ទាន់មកក្រសួងដើម្បីមានវិធានការបន្ត។

ប្រការ ៥-

មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវប្រើប្រាស់គំរូលិខិត ឯកសារទាំងឡាយ ដូចមានចែងក្នុងបញ្ជីនៃឧបសម្ព័ន្ធដែលភ្ជាប់ជាមួយប្រកាសនេះ ឬ តាមការណែនាំផ្សេងៗទៀតរបស់ក្រសួង។

ប្រការ ៦-

ការត្រួតពិនិត្យលើការប្រតិបត្តិអាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតបើករកស៊ីកម្មសាលបម្រើសេវាអ៊ីនធឺណេតកាហ្វេ (Internet café) ការលក់-ដូរសម្ភារៈបរិក្ខារវិទ្យុគមនាគមន៍និងបរិក្ខារទូរគមនាគមន៍ និងការប្រើប្រាស់ហ្វ្រេកង់ស៍តាមបណ្តាខេត្តនីមួយៗ ជាសមត្ថកិច្ចរបស់មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តនោះ។

ក្នុងករណីចាំបាច់ មន្ត្រីនៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវសុំសហការពីអាជ្ញាធរមានសមត្ថកិច្ច។

ប្រការ ៧-

ប្រាក់ចំណូលបានមកពីការគ្រប់គ្រងសេវាអ៊ីនធឺណេត និង វិទ្យុគមនាគមន៍ត្រូវបង្វែរចូលក្នុងធនាគារខេត្ត ក្នុងជំពូកថវិការបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ មិនឲ្យលើសពីរយៈពេល ៣០ថ្ងៃ។

ប្រការ ៨-

រាល់ប្រកាសទាំងឡាយណាដែលមានន័យផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៩-

ខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានប្រៃសណីយ៍និងទូរគមនាគមន៍ អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋានចំណុះក្រសួង និង គ្រប់មន្ទីរប្រៃសណីយ៍និងទូរគនាមនាគមន៍មានភារកិច្ចអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពខ្ពស់។

ប្រការ ១០-

ប្រកាសនេះត្រូវចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ តុលា ឆ្នាំ២០១០

**រដ្ឋមន្ត្រី**

សូ ខុន

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម-លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងការពារជាតិ
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាលារាជធានី-ខេត្ត
- "ដើម្បីជូនជ្រាប"
- ដូចប្រការ៩ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ